ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៤៦/១៣-ខេម ហ្វអេវើ
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង វួចហ៊ុន**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **អាំង អេងថុង**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ខេម ហ្វអេវើ ខូ អិលធីឌី**

អាសយដ្ឋាន ៖ ភូមិឬស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៩៧ ២ ០០០ ៦៨៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី១ ៖

១- លោក លី សុគន្ធ រដ្ឋបាល
២- លោក ឡា វី ជំនួយការនាយក

តំណាងភាគីនិយោជកចូលរួមសវនាការលើកទី២ ៖

១- លោក លី សុគន្ធ រដ្ឋបាល
២- លោក ឡា វី ជំនួយការនាយក

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា**

អាសយដ្ឋាន ៖ ផ្លូវវែងស្រេង ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥១ ៩៥ ៦០/០៩៧ ៧ ៥១៩ ៥៦០ ទូរសារ ៖ គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារៈ ០២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី១ ៖

១-លោក ម៉ាន់ សាបាន ប្រធានសហព័ន្ធសហជីពស្ថាបនាសិទ្ធកម្មករ (UFIWR)

២-លោក ស៊ុន សុភ័ក្រ្ត មន្រ្តីសហជីពស្មារតីកម្មករកម្ពុជា

៣-កញ្ញា សាន់ ចាន់ធឿន ប្រធានសហជីពស្មារតីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ

តំណាងកម្មករនិយោជិតចូលរួមសវនាការលើកទី២ ៖ អវត្តមាន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១-កម្មករនិយោជិតនៃក្រុមហ៊ុន ខេម ហ្វអេវើ នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមសេចក្តីជូនដំណឹងលេខ ២៣០ កប/សជណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២។

២-កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់លុយព្រឹមចំនួន ១៥ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនអនុវត្តទៅតាមសេចក្តីជូនដំណឹងលេខ ២៣០ កប/សជណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២។

៣-កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលគោលរបស់កម្មករ ៧០ ដុល្លារ ទាំងអស់គ្នា។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ។

៤-កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់លុយបាយថែមម៉ោង ១ ម៉ោង ១០០០ រៀល បន្ថែមទៀតលើលុយបាយដែលមានសព្វថ្ងៃ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចផ្តល់ជូនបានទេ ក្រុមហ៊ុនអនុវត្តតាមគោលការណ៍កន្លងមក។

៥-កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនអនុវត្តការឈប់សម្រាកពិសេសទៅតាមច្បាប់ស្តីពីការងារ ដោយផ្តល់ប្រាក់ឈ្នួលប្រាំថ្ងៃភ្លាមៗ ឱ្យកាត់បំណាច់ឆ្នាំ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនឱ្យឈប់សម្រាកពិសេសដោយកាត់ប្រាក់ឈ្នួលប្រចាំថ្ងៃ(ទៅតាមថ្ងៃឈប់) ហើយមិនកាត់បំណាច់ឆ្នាំ និងរក្សាលុយព្រឹមដដែល។

៦-កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនប្តូរបន្ទប់ពេទ្យមកដាក់ខាងក្រោម និងជិតកម្មករធ្វើការវិញ។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនអាចធ្វើទៅតាមសំណូមពររបស់កម្មករបានទេ។

៧-កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលឱ្យមុន ៣ ខែ ចំពោះកម្មការិនីឆ្លងទន្លេ (ឈប់សម្រាកលំហែមាតុភាព) និងសុំគិតតាមសមាមាត្រតាមនៃប្រាក់ឈ្នួលទាំងអស់។ ដោយឡែកភាគីតំណាងក្រុមហ៊ុនបញ្ជាក់ថាករណីនេះ ក្រុមហ៊ុនធ្វើការផ្តល់ជូនតែទៅតាមផ្លូវច្បាប់កំណត់តែប៉ុណ្ណោះ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩

THE ARBITRATION COUNCIL

សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ២២២ កប/អក/វក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** - ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។
- ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៣ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក)។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងទាមទាររបស់សហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា លេខ ៦២/១២ សសក ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការទាមទារឱ្យក្រុមហ៊ុន ខេម ហ្វូអេវើ កែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានធ្វើលិខិតអញ្ជើញភាគីកម្មករនិយោជិត និងភាគីនិយោជកមកសាកសួរព័ត៌មាននៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ នៅនាយកដ្ឋានវិវាទការងារ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន ០៧ ចំណុច លើការទាមទារចំនួន ២២ ចំណុច។ ចំណុចមិនសះជាចំនួន ០៧ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមមិនសះជាលេខ ២២២ ក.ប/អក/វក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីទាំងពីរមកសវនាការលើកទី១ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរមានវត្តមាននៅថ្ងៃសវនាការលើកទី១ តាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ប៉ុន្តែ អាជ្ញាកណ្តាលដែលជ្រើសរើសដោយភាគីនិយោជកបានអវត្តមាន ដោយមានធុរៈជាចាំបាច់ ដូចនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ប្រាប់ភាគីទាំងពីរថា នឹងមានសវនាការលើកទី២ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក។ នៅថ្ងៃសវនាការលើកទី២ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០ នាទី ព្រឹក លេខាធិការដ្ឋានបានទំនាក់ទំនងតាមទូរស័ព្ទទៅកាន់ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹង ប៉ុន្តែលោក លី ចាន់សុភក្តិ ជាប្រធានសហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា បានប្រាប់មកលេខាធិការដ្ឋានថា ប្រធានសហជីពស្មារតីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន ខេម ហ្វូអេវើ មានជំងឺមិនអាចមកចូលរួមសវនាការបានទេ។ ចំណែកឯ ថ្នាក់ដឹកនាំសហជីពស្មារតីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន



THE ARBITRATION COUNCIL

ខេម ហ្វអេវើ ផ្សេងៗទៀត ក៏មិនអាចមកចូលរួមសវនាការបានដែរ ពីព្រោះថា ពួកគាត់មិនបានដឹងរឿងដែលទាក់ទងចំណុចវិវាទដែលមានក្នុងសំណុំរឿងលេខ ៤៦/១៣ ខេម ហ្វអេវើ ទេ។ លោក លី ចាន់សុភក្តិ បានបញ្ជាក់ទៀតថា មន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា ក៏មិនមានមន្ត្រីសហព័ន្ធសហជីពណាម្នាក់អាចចូលរួមក្នុងសវនាការបានដែរ។ បញ្ជាក់៖ សហព័ន្ធសហជីពស្ថាបនាសិទ្ធកម្មករ និងសហព័ន្ធ សហជីពស្មារតីកម្មករកម្ពុជា គឺស្ថិតនៅក្រោមសហភាពជាតិកម្ពុជាការពារកម្មករតែមួយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតប្រគល់សិទ្ធិរបស់នាយកក្រុមហ៊ុន ខេម ហ្វអេវើ ផ្ទេរសិទ្ធិជូនលោក លី សុគន្ធ និងលោក ឡា វី ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣។

២- សារណាសង្ខេបនៃវិវាទការងារ លេខ ០០៦/១៣ C4E ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣។

២- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ចុះបញ្ជិកាលេខ ០៥៤ កប/អក/អធក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២។

៣- លក្ខន្តិកៈក្រុមហ៊ុន ខេម ហ្វអេវើ តំកល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម លេខ ២៣៤៩/២០១១ ពណ. ចបព ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១។

៤- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ៤៨៧៩ ពណ.ចបព ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១១។

៥- លិខិតលេខ ៦៧០ កប/អក/វក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១២ របស់ប្រធាននាយកដ្ឋានវិវាទការងារ ជម្រាបមក នាយកក្រុមហ៊ុន ខេម ហ្វអេវើ ស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិទី ១។

៦- សេចក្តីជូនដំណឹងលេខ ២៣០ កប/សជណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១២។

៧- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ខេម ហ្វអេវើ លេខ ០១៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ស្តីពីប្រាក់ធ្វើការទៀងទាត់។

៨- សេចក្តីជូនដំណឹងលេខ ០៤៩/១០ កប/សជណ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០។

៩- សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ខេម ហ្វអេវើ ស្តីពីប្រាក់ខែគោល។

១០-សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ខេម ហ្វអេវើ លេខ ០១២ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការឈប់សម្រាកពិសេស និងការឈប់សម្រាកប្រចាំឆ្នាំ ។

១១-សេចក្តីជូនដំណឹងលេខ ០៤១/១១ កប/សជណ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១។

១២-សេចក្តីជូនដំណឹងរបស់ក្រុមហ៊ុន ខេម ហ្វអេវើ លេខ ០១១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការផ្តល់ថ្លៃបាយ។

THE ARBITRATION COUNCIL

១៣-កិច្ចព្រមព្រៀង ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១២ រវាងថ្នាក់ដឹកនាំក្រុមហ៊ុន ខេម ហ្វអេវើ និង តំណាងកម្មករនិយោជិតទាក់ទងនឹងការធ្វើការថែមម៉ោងថ្ងៃអាទិត្យ។

១៤-កិច្ចសន្យាជួលរោងចក្រ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១។

១៥-របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១២, ប្រចាំខែមករា និងខែកុម្ភៈ ឆ្នាំ២០១៣ របស់នាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

១៦-តារាងបុគ្គលិកក្រុមហ៊ុន ខេម ហ្វអេវើ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេម ហ្វអេវើ លេខ ២២២ កប/អក/វក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ខេម ហ្វអេវើ ចុះថ្ងៃទី១៤ខែកុម្ភៈ ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២២៨ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ ។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២២៩ កប/អក/វក/លកអ. ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៣ ។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៦០ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ ។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២៦១ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ ។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារថ្នាក់ដឹកនាំ ឬតំណាងសហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា និងសហជីពកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ ដែលជាដើមបណ្តឹងមិនបានមកចូលរួមសវនាការលើកទី២។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ លោក លី ចាន់សុភក្តិ ដែលជាប្រធានសហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា បានប្រាប់មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមរយៈទូរស័ព្ទថា ប្រធានសហជីពស្មារតីកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ មានជំងឺមិនអាចចូលរួមក្នុងសវនាការបានទេ។ ចំណែកឯ ថ្នាក់ដឹកនាំសហជីពផ្សេងទៀត មិនបាន

THE ARBITRATION COUNCIL

មកចូលរួមសវនាការ ពីព្រោះថា ពួកគាត់មិនបានដឹងអំពីចំណុចវិវាទក្នុងសំណុំរឿងនេះទេ។ បន្ថែមលើសទៀត លោក លី ចាន់សុភក្តិ បានបញ្ជាក់ថា មិនមានមន្ត្រីសហព័ន្ធសហជីពណាម្នាក់អាចចូលរួមក្នុងសវនាការបានដែរ។

នៅក្នុងសំណុំរឿងនេះ ៖

១. នៅថ្ងៃសវនាការ នៅពេលដែលមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទូរស័ព្ទទៅភាគីកម្មករនិយោជិត ភាគីកម្មករនិយោជិតបានស្នើសុំពន្យារពេលសវនាការ ដោយមិនបានជូនដំណឹងជាលាយល័ក្ខណ៍អក្សរមកក្រុមប្រឹក្សាអាជ្ញាកណ្តាលមុនពេលសវនាការលើកទី២ ចាប់ផ្តើមនោះទេ។

២. ការស្នើសុំពន្យារពេលសវនាការនេះ ត្រូវបានធ្វើឡើង ដោយយោងលើមូលហេតុនៃការអវត្តមានរបស់ប្រធានសហជីពមូលដ្ឋានដោយមាជំងឺ ប៉ុន្តែលោក លី ចាន់សុភក្តិ មិនអាចបញ្ជាក់បានថា តើមានជំងឺអ្វី ឬមានឱ្យបុគ្គលិកណាមួយមកជំនួសគាត់នោះទេ។ ម្យ៉ាងវិញទៀត ថ្នាក់ដឹកនាំផ្សេងៗទៀតរបស់សហីពស្មារតីកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ ក៏មិនបានមកចូលរួមសវនាការដែរ។ លើសពីនេះទៀត លោក លី ចាន់សុភក្តិ បានបញ្ជាក់ថា មិនមានមន្ត្រីសហព័ន្ធសហជីពណាម្នាក់មកចូលរួមសវនាការបានដែរ។

យោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច មិនពន្យារពេលសវនាការតាមការស្នើសុំរបស់លោក លី ចាន់សុភក្តិ ឡើយ។

ជាបន្ត ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនឹងត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ ក្នុងករណីអវត្តមានដើមបណ្តឹង?

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់"*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍ និងលេខ ១៣១/១២-ម៉ាស្ទ័រ & ប្រែុង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយប្រការ២១ ខាងលើនេះថា មានលក្ខខណ្ឌបីដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចមិនបន្តដំណើរការអាជ្ញាកណ្តាល *លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ, លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល* និង*លក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន"*។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗខាងលើដែរ។ ហេតុនេះ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី១ ៖ *ភាគីត្រូវបានអញ្ជើញត្រឹមត្រូវ***

មន្ត្រីលេខាធិការដ្ឋានបានទំនាក់ទំនងទៅកាន់ដើមបណ្តឹង ដោយជូនដំណឹងពីសវនាការលើកទី២ តាមរយៈការប្រាប់ដោយផ្ទាល់មាត់ បន្ទាប់ពីសវនាការលើកទី១ និងលិខិតអញ្ជើញលេខ ២៦០ កប/អក/វក/លកអ. ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៣ ដោយបានទទួលនូវការចុះហត្ថលេខាទទួលពីឈ្មោះ ម៉ាន់ សាបាន ដែលជាប្រធានសហព័ន្ធសហជីពស្ថាបនាសិទ្ធកម្មករ (UFTWR) នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ ២០១៣។ នៅថ្ងៃសវនាការនាលើកទី២ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៣ លេខាធិការដ្ឋានបានទំនាក់ទំនងតាមទូរស័ព្ទទៅកាន់លោក លី ចាន់សុភក្តិ ដែលជាសហព័ន្ធសហជីពស្មារតីកម្មករកម្ពុជាទៀត ប៉ុន្តែ លោក លី ចាន់សុភក្តិ បានប្រាប់មកមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលថា ប្រធានសហជីពស្មារតីកម្មករកម្ពុជាប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ មានជំងឺមិនអាចមកចូលរួមសវនាការបានទេ។ លើសពីនេះ លោក លី ចាន់សុភក្តិ បានបន្តទៀតថា គ្មានមន្ត្រីសហព័ន្ធសហជីព ឬថ្នាក់ដឹកនាំសហជីពស្មារតីមូលដ្ឋាន មកចូលរួមសវនាការនាទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីដើមបណ្តឹងពិតជាទទួលបានការអញ្ជើញត្រឹមត្រូវ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "*ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល*" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះ មានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតចប់សព្វគ្រប់។ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ ប្រធានសហជីពស្មារតីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ ព្រមទាំងថ្នាក់ដឹកនាំផ្សេងៗទៀតរបស់សហជីពស្មារតីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ មិនបានអញ្ជើញមកចូលរួមសវនាការអាជ្ញាកណ្តាលទេ។ លើសពីនេះ ថ្នាក់ដឹកនាំ ឬមន្ត្រីសហព័ន្ធសហជីពស្មារតីកម្មករកម្ពុជា ក៏មិនបានមកចូលរួមសវនាការដែរ។

THE ARBITRATION COUNCIL

ហេតុនេះ ភាគីដើមបណ្តឹងមិនមានវត្តមាននៅក្នុងសវនាការ ហើយក៏មិនបានចូលរួមគ្រប់ដំណាក់កាលទាំងបួនខាងលើនេះ ក្នុងន័យនេះ គឺភាគីដើមបណ្តឹងមិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល តាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ២១ ខាងលើនេះទេ។ ដូចនេះ លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី៣ ៖ ភាគីមិនបានបង្ហាញមូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

នៅថ្ងៃសវនាការ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទំនាក់ទំនងតាមទូរស័ព្ទរំលឹកទៅភាគីដើមបណ្តឹង អំពីការចូលរួមសវនាការអាជ្ញាកណ្តាល ប៉ុន្តែភាគីដើមបណ្តឹងបានឆ្លើយថា ប្រធានសហជីពស្មារតីកម្មករកម្ពុជា ប្រចាំក្រុមហ៊ុន ខេម ហ្វអេវើ មានជំងឺមិនអាចមកចូលរួមសវនាការបានទេ។ លើសពីនេះ លោក លី ចាន់សុភក្តិ ប្រាប់ទៀតថា ថ្នាក់ដឹកនាំសហជីពមូលដ្ឋានផ្សេងទៀត ក៏មិនអាចចូលរួមសវនាការទេ។ មួយវិញទៀត លោក លី ចាន់សុភក្តិ មិនបានប្រាប់ពីមូលហេតុដែលថ្នាក់ដឹកនាំសហជីពមូលដ្ឋានផ្សេង មិនអាចចូលរួមសវនាការទេ ដោយគ្រាន់តែបានបញ្ជាក់ថា ថ្នាក់ដឹកនាំសហជីពមូលដ្ឋានផ្សេងទៀតមិនបានដឹងពីចំណុចវិវាទដែលមានក្នុងសំណុំរឿងលេខ ៤៦/១៣-ខេម ហ្វអេវើ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីដើមបណ្តឹងមិនបានបង្ហាញនូវមូលហេតុជាក់លាក់សម្រាប់ការមិនបង្ហាញខ្លួននេះទេ។ មួយវិញទៀត លោក លី ចាន់សុភក្តិ បានបញ្ជាក់ថា ថ្នាក់ដឹកនាំផ្សេងទៀតមិនបានដឹងពីចំណុចវិវាទក្នុងសំណុំរឿងនេះ គឺមិនមានហេតុផលសមរម្យនោះទេ ពីព្រោះសហជីពស្មារតីកម្មករកម្ពុជាដែលជាដើមបណ្តឹង មានថ្នាក់ដឹកនាំសហជីព ចំនួន ៣ រូប ដែលមានសិទ្ធស្របច្បាប់ក្នុងការតំណាងកម្មករនិយោជិតជាសមាជិករបស់ពួកគាត់។ ដូចនេះ បើសិនមានថ្នាក់ដឹកនាំសហជីពណាម្នាក់ ក្នុងចំណោម ៣ រូបមិនអាចមកចូលរួមសវនាការ គឺមានថ្នាក់ដឹកនាំ ២ រូបផ្សេងទៀត ដែលអាចមកចូលរួមសវនាការបាន ។ ដូច្នេះ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

ហេតុនេះ ផ្អែកតាមវិធាន និងប្រកាស ព្រមទាំងការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ដើមបណ្តឹងបានបោះបង់ចោលពាក្យបណ្តឹងរបស់ខ្លួន។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញសេចក្តីបង្គាប់។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ **៤៦/១៣ -ខេម ហ្វអេវើ** នេះទេ។

យោងតាមហេតុផលខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច ដូចតទៅ ៖

## សម្រេច និង បង្គាប់

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ **៤៦/១៣ -ខេម ហ្វអេវើ** ។

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេង ទួចហ៊ុន**

ហត្ថលេខា ៖ ------------------------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ឈាន**

ហត្ថលេខា ៖ ------------------------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **អាំង អេងថុង**

ហត្ថលេខា ៖ ------------------------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL